# ការវាយតម្លៃបឋម

## អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)

## ក្រសួងបរិស្ថាន (MoE)

លេខយោង : 000004

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២

អនុក្រឹត្យEIA ត្រូវបានជ្រើសរើសយកមកអនុវត្ត វ.ផ.ល. សម្រាប់បង្ហាញដល់មន្ត្រីក្រសួងបរិស្ថាន ពីព្រោះវាមានផលប៉ះពាល់ដល់ក្រុមហ៊ុន (ក្រុមហ៊ុនបច្ចុប្បន្ន និងកំពុងស្នើសុំ) និងដល់សេដ្ឋកិច្ច។ អនុក្រឹត្យនេះក៏ប៉ះពាល់ដល់បរិស្ថាននិងសហគមន៍ទាំងមូលដែរ។ ទោះបីវាជាអនុក្រឹត្យដែលមានស្រាប់ ប៉ុន្តែមានសារៈសំខាន់ និងមានលក្ខណៈល្អក្នុងការអនុវត្ត វ.ផ.ល.។

គ្រប់ក្រុមហ៊ុនទាំងអស់តម្រូវឲ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង(IEIA) សម្រាប់ក្រុមហ៊ុនតូច ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ(EIA) សម្រាប់ក្រុមហ៊ុនធំ រួចដាក់ជូន MoE។

នៅក្នុងបរិយាកាសដែលមិនមានការគ្រប់គ្រងដោយបញ្ញត្តិកម្ម ធុរកិច្ចអាចបង្កកត្តាសាយភាយទៅលើសុខភាពសាធារណៈ(សារធាតុបំពុល) និងបរិស្ថាន(ការផ្លាស់ប្តូរជម្រករបស់ត្រី)។ អនុក្រឹត្យនេះមានបំណងការពារកត្តាសាយភាយបែបនេះ។

ជម្រើសដែលអាចអនុវត្តបានចំនួនពីរត្រូវបានយកមកវាយតម្លៃ គឺប្រើឥទ្ធិពលលើធុរកិច្ចតាមរយៈអ្នកផ្តល់ជំនួយ និងយុទ្ធនាការលើកកម្ពស់ការយល់ដឹងដល់សាធារណជន។ ជម្រើសទាំង២នេះ មិនមានបន្ទុកចំណាយកាតព្វកិច្ចគួរឲ្យកត់សម្គាល់ទេ។ អនុក្រឹត្យនេះក៏មានផលចំណេញច្រើនដែរ ពីព្រោះវាអនុញ្ញាតឲ្យរដ្ឋាភិបាលប្រមូលព័ត៌មានដែលអាចប្រើប្រាស់បាន ដើម្បីឆ្លើយតបយ៉ាងរហ័សចំពោះគ្រោះមហន្តរាយបរិស្ថានដែលកើតឡើង។ បន្ថែមលើជម្រើសទាំង២នេះ ជម្រើស៣ផ្សេងទៀតត្រូវបានយកមកពិចារណា ប៉ុន្តែមិនបានធ្វើការវាយតម្លៃទេ ពីព្រោះជម្រើសទាំងនេះមិនអាចធ្វើទៅបាន។

# ការវាយតម្លៃបឋម

## អនុក្រឹត្យស្ដីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)

## ក្រសួងបរិស្ថាន

លេខយោង : 00000៤

កាលបរិច្ឆេទចាប់ផ្ដើម : ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១២

(នេះគឺជាអនុក្រឹត្យដែលមានស្រាប់និងបានចូលជាធរមានរួចហើយ។ ការធ្វើ PA លើអនុក្រឹត្យនេះក្នុងគោលបំណងបណ្ដុះបណ្ដាលប៉ុណ្ណោះ។ ដូច្នេះ PA នេះគ្រាន់តែឧទាហរណ៍។)

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២

**ទំនាក់ទំនង :**

| | **ឈ្មោះ** | **លេខទូរស័ព្ទ** | Email |
|---|---|---|---|
| IA-ទទួលបន្ទុក | លោក យិន សំរ៉ាយ | 011 87 15 41<br>097 752 56 77 | yinsamray@gmail.com |
| IA-ជំនួស | លោក រស់ ជ័រ | 012 98 60 98 | roschor@gmail.com |
| ORIA-ទទួលបន្ទុក | លោកស្រី លឹម សុគន្ធា | 092 73 69 69 | lskthea@yahoo.com |
| ORIA-ជំនួស | លោក ជា ពិសិដ្ឋនរៈ | 012 90 81 61 | ps_norak@yahoo.com |

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

អនុក្រឹត្យនេះតម្រូវឱ្យក្រុមហ៊ុនទាំងឡាយរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA)/របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ(EIA) និងដាក់មកក្រសួងបរិស្ថានស្នើសុំការអនុម័ត មុននឹងចាប់ផ្ដើមប្រតិបត្តិការ។ អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគម្រោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការលើកលែងគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសម្រេចដោយរាជរដ្ឋាភិបាល។(អនុក្រឹត្យ នេះចាត់ទុកជាជម្រើសទី១នៅក្នុងការវាយតម្លៃនេះ)

## តើសំណើនេះមានចរិកជាបញ្ញត្តិកម្មដែរឬទេ?

តើវាផ្លាស់ប្តូរតវិយាបទធុរកិច្ចដែរឬទេ? មែន

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ច្បាប់ | | ព្រះរាជក្រឹត្យ | | អនុក្រឹត្យ | ✔ | ប្រកាស | | សេចក្តីសម្រេច | | សារាចរ | | ផ្សេងៗ |

## តើសំណើបញ្ញត្តិនេះមានផលប៉ះពាល់លើវិស័យធុរកិច្ចដែរឬទេ? មែន

## ១. បញ្ហា- ហេតុអ្វីបានជាយើងធ្វើបញ្ញត្តិនេះឡើង?

| ប្រធានបទទូទៅ | | ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ប្រសិនបើចាំបាច់) |
|---|---|---|
| សុខភាព និងសុវត្ថិភាពសាធារណៈ | មែន | សារធាតុពុលមានផលប៉ះពាល់ដល់សុខភាព ត្រូវបានដឹងឮជាទូទៅ (ឧទាហរណ៍ ករណីឧប្បត្តិហេតុបង្កដោយ ក្រុមហ៊ុន Union Carbide នៅខេត្តបូផាល់ប្រទេស ឥណ្ឌា)។<br><br>ហានិភ័យ ដែលអាចកើតឡើងនៅកម្ពុជារួមមាន ៖<br><br>• ការជីកយករ៉ែមាស ដោយប្រើម្សៅគេអ៊ិនតេ ប្រសិនបើមិនបានចាត់ចែងឲ្យបានត្រឹមត្រូវ វាអាចបំពុលទឹក ដោយសារធាតុបារតនិងសារធាតុគីមីស្យានីត (cyanide) ហើយប៉ះពាល់ដល់សុខភាពសាធារណៈ។ (យោងតាមរបាយការណ៍ ក្រសួងបរិស្ថាន /UNIDO ឆ្នាំ២០១១)។<br><br>• ការចម្រាញ់យករ៉ែបុកស៊ីតអាលុយមីញ៉ូម ដោយប្រើសំណារ អាចធ្វើឲ្យទឹកកខ្វក់ និងមានឥទ្ធិពលអាក្រក់ដល់ខួរក្បាលមនុស្ស។ |
| ការការពារ និងអភិរក្សបរិស្ថាន | មែន | មានបញ្ហាបរិស្ថានជាច្រើនករណីដែលគួរឲ្យបារម្ភ។<br>ឧទាហរណ៍ ការសាងសង់ទំនប់វារីអគ្គីសនីនៅតាមទន្លេមេគង្គ ដែលអាចធ្វើឲ្យផ្លាស់ប្តូររបបទឹកហូរ ប្រព័ន្ធជីវចម្រុះ ការផ្លាស់ប្តូរទីកន្លែងរបស់ត្រី ដីសណ្ត។ល។ |
| សមធម៌យេនឌ័រ ការអភិរក្សសង្គម និង វប្បធម៌ | មែន | ការបំពុលបរិស្ថានអាចប៉ះពាល់ដល់អ្នកភូមិ ដែលមានជីវភាពរស់នៅពឹងអាស្រ័យលើបរិស្ថានដូចជាទន្លេ នឹងបង្កឲ្យមានបញ្ហាដល់សង្គម។ មិនតែប៉ុណ្ណោះ ស្ត្រីនៅតាមជនបទភាគច្រើនជាកសិករ ចំណែកបុរសជាអ្នកនេសាទ ដែលសុទ្ធតែអាចទទួលរងនូវផលប៉ះពាល់ផ្សេងៗ ដោយសារការបំពុលបរិស្ថាន (យោងតាមរបាយ |

| | | |
|---|---|---|
| | | ការណ៍ របស់លោកបណ្ឌិត ឈុន វណ្ណៈ អំពីករណីសិក្សាការវាយតម្លៃភាពរងគ្រោះ និងការពិនិត្យតាមដានផលប៉ះពាល់សង្គមនៅខេត្តសៀមរាប និងពោធិ៍សាត់ ខែមករា ឆ្នាំ២០១១) |
| ជម្រុញការប្រកួតប្រជែង | មិនមែន | |
| ការប្រមូលផ្តុំព័ត៌មាន | មែន | របាយការណ៍ IEIA ផ្តល់ព័ត៌មានរួមដល់រាជរដ្ឋាភិបាល ដោយឡែក EIA ផ្តល់ឲ្យរដ្ឋាភិបាលនូវព័ត៌មានទូលំទូលាយ ដើម្បីស្វែងយល់អំពីបញ្ហា និងយន្តការរារាំងកុំឲ្យបញ្ហាកាន់តែរីកដុះដាលធំឡើង (ទប់ស្កាត់/ដោះស្រាយ) |
| អនុលោមតាម កិច្ចព្រមរបស់(WTO) និងកិច្ចព្រមព្រៀងអន្តរជាតិនានា | មែន | ប្រទេសកម្ពុជាជាហត្ថលេខីនៃកម្មវិធីបរិស្ថាន មានដូចជា UNEP។ |

## ប្រសិនបើមានបញ្ហាផ្សេងទៀត ចូរពន្យល់និងផ្តល់ភស្តុតាង

គ្មាន

## សូមបញ្ជាក់ថាតើបញ្ញត្តិកម្មនេះនឹងធ្វើឲ្យស្ថានការណ៍ប្រសើរឡើងយ៉ាងដូចម្តេច?

អនុក្រឹត្យ EIA តម្រូវឲ្យក្រុមហ៊ុនផ្តោតលើហេតុប៉ះពាល់បរិស្ថាននិងសង្គមដែលអាចកើតចេញពីដំណើរប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

## ២. គោលបំណង - តើយើងចង់សម្រេចអ្វី?

កាត់បន្ថយការខូចខាតបរិស្ថាននិងរួមចំណែកដល់ការអភិវឌ្ឍដោយចីរភាពក្នុងប្រទេសកម្ពុជា (ឧទាហរណ៍ ជៀសវាងការធ្វើឲ្យទឹកកខ្វក់ ពីព្រោះវាអាចកាត់បន្ថយផលិតភាព)។

## ៣. ជម្រើស- ពិចារណាជម្រើសផ្សេងៗទាំងឡាយ

### ៣.ក. សូមរាយបញ្ជីបញ្ញតិកម្ម(ដែលមានស្រាប់) ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា ៥៨ និង មាត្រា៥៩ មានយោងអំពីបញ្ហាបរិស្ថាន ហើយម្យ៉ាងទៀតមានច្បាប់ពាក់ព័ន្ធផ្សេងទៀត ៖

១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ

២. ប្រកាសស្តីពីគោលការណ៍ណែនាំស្តីពីការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនិងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឆ្នាំ២០០៩

៣. ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨

៤. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ២០០៧

៥. ច្បាប់ស្តីពីព្រៃឈើ

៦. ច្បាប់ស្តីពីជលផល

៧. ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម

៨. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក

៩. អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង

១០. ច្បាប់ស្តីពីជីវសុវត្ថិភាព

១១. អនុក្រឹត្យស្តីពីការបំពុលខ្យល់និងការរំខានដោយសម្លេង

១២. ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ

### ចូរបញ្ជាក់ថាតើហេតុអ្វីបានជាលិខិតបទដ្ឋានទាំងនេះមិនទាន់គ្រប់គ្រាន់?

លិខិតបទដ្ឋានគតិយុត្តទាំងអស់ខាងលើនេះមានគោលបំណងទូទៅ។ ក៏ប៉ុន្តែ EIA អាចប្រមូលព័ត៌មានទាក់ទិននឹងបរិស្ថានទាំងអស់ឲ្យមានលក្ខណៈស្តង់ដារ សម្រួលដល់គម្រោងអាជីវកម្មក្នុងការដោះស្រាយបញ្ហាបរិស្ថានដែលអាចកើតឡើង ដែលកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងចូលរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

ជម្រើសដំទៃទៀត

## ៣.ខ. ជម្រើសដទៃទៀតដែលអាចអនុវត្តបាន (សម្រាប់ការវិភាគលើផលប៉ះពាល់)

២. ប្រើឥទ្ធិពលរបស់អ្នកផ្តល់ជំនួយមកលើក្រុមហ៊ុន ដូចជា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) មូលនិធិអភិវឌ្ឍបច្ចេកវិទ្យារបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) រដ្ឋាភិបាលម្ចាស់ជំនួយ(ប្រទេសចិនជាឧទាហរណ៍) ដើម្បីតម្រូវឲ្យអនុវត្តតាម EIA។

៣. យុទ្ធនាការអប់រំផ្សព្វផ្សាយដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុ (កម្ចីបរិស្ថានរបស់ធនាគារអេស៊ីលីដា)

## ៣.គ. ជម្រើសដទៃទៀតដែលតាមទ្រឹស្តីអាចមាន ប៉ុន្តែមិនអាចអនុវត្តបាន

១. គោលការណ៍ណែនាំរបស់រដ្ឋាភិបាល ឧទាហរណ៍គោលការណ៍ណែនាំតាមវិស័យ គឺវិស័យនីមួយៗមានគោលការណ៍ការណែនាំផ្សេងៗគ្នា ចុះហត្ថលេខាដោយរដ្ឋមន្ត្រី ដែលតម្រូវឲ្យក្រុមហ៊ុនមានការវាយតម្លៃស្រដៀងគ្នា។ គោលការណ៍នេះផ្តល់លទ្ធផលប្រហាក់ប្រហែលនឹងអនុក្រឹត្យEIA ក៏ប៉ុន្តែយន្តការសម្រាប់ធ្វើឲ្យសម្រេចគោលបំណង ជួបការលំបាក ដោយពឹងផ្អែកលើការបញ្ចុះបញ្ចូលក្រសួងខ្លះ ដើម្បីឲ្យអនុវត្ត។

២. ចុះកិច្ចព្រមព្រៀងជាមួយប្រទេសផ្សេងទៀតទាក់ទិននឹងបញ្ហាហេតុប៉ះពាល់បរិស្ថានឆ្លងដែន-ប៉ុន្តែជម្រើសនេះ ពិបាក អនុវត្ត ដោយសារវានៅក្រៅដែនសមត្ថកិច្ចរាជរដ្ឋាភិបាលកម្ពុជា។

៣. ដំណោះស្រាយតាមប្រព័ន្ធច្បាប់បែបអង់គ្លេស ច្បាប់តឹងរឹង និងពង្រឹងការអនុវត្តច្បាប់ឲ្យបានតឹងតែង ដោយតម្រូវឲ្យក្រុមហ៊ុនដែលបំពុលបរិស្ថានបង់ប្រាក់ពិន័យយ៉ាងច្រើន ដែលអាចធ្វើឲ្យក្រុមហ៊ុនជួបប្រទះហានិភ័យហិរញ្ញវត្ថុធ្ងន់ធ្ងរ ប៉ុន្តែកម្ពុជាអនុវត្តប្រព័ន្ធច្បាប់បែបបារាំង ដែលធ្វើឲ្យជម្រើសនេះមិនអាចអនុវត្តបាន។

## ៤. ការប៉ាន់ស្មានបឋមចំណាយភាគពូកិច្ច និងផលប៉ះពាល់ចំពោះការប្រកួតប្រជែង

### ៤.១. ការកំណត់នូវតារកិច្ច និងប្រភេទចំណាយ

### ៤.២. វិសាលភាពនៃជម្រើស

ប្រភេទចំណាយ(៤.១.)និងវិសាលភាព(៤.២) មានភ្ជាប់នៅទំព័រខាងក្រោយ ដែលមានការប៉ាន់ស្មានពីចំណាយសរុបនៃជម្រើសនីមួយៗ។

### ៤.៣. ប៉ាន់ស្មានកម្រិតកំណើននៃចំណាយកាតព្វកិច្ចរបស់ធុរកិច្ច និងរបស់រាជរដ្ឋាភិបាល

| ធុរកិច្ច | កម្រិតកំណើននៃចំណាយកាតព្វកិច្ច | អំណះអំណាង(មើលទំព័រខាងក្រោយ) |
|---|---|---|
| ជម្រើសទី១ | គួរឲ្យកត់សម្គាល់ | មានចំណាយច្រើនលើការរៀបចំរបាយការណ៍ IEIA/EIA ដោយផ្អែកលើប្រភេទ និងទំហំនៃគម្រោង។ |
| ជម្រើសទី២ | មិនគួរឲ្យកត់សម្គាល់ | មិនមានបន្ទុកចំណាយ |
| ជម្រើសទី៣ | មិនគួរឲ្យកត់សម្គាល់ | មិនមានបន្ទុកចំណាយ |

| រាជរដ្ឋាភិបាល | កម្រិតកំណើននៃចំណាយកាតព្វកិច្ច | អំណះអំណាង |
|---|---|---|
| ជម្រើសទី១ | មិនគួរឲ្យកត់សម្គាល់ | វាយតម្លៃនិងអធិការកិច្ចប៉ុណ្ណោះ |
| ជម្រើសទី២ | មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយតែលើបុគ្គលិកប៉ុណ្ណោះ |
| ជម្រើសទី៣ | គួរឲ្យកត់សម្គាល់ | ទូរទស្សន៍ សិក្ខាសាលា...។ល។ មានតម្លៃថ្លៃ។ |

## ៤.៤. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | កម្រិតនៃផលចំណេញ | មូលហេតុ |
|---|---|---|
| ជម្រើសទី១ | គួរឲ្យកត់សម្គាល់ | ផ្តល់ប្រព័ន្ធនិងស្តង់ដារវាយតម្លៃបរិស្ថានសម្រាប់ក្រុមហ៊ុន |
| ជម្រើសទី២ | មិនគួរឲ្យកត់សម្គាល់ | អនុវត្តចំពោះតែគម្រោងដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយប៉ុណ្ណោះ មិនគ្រប់ដណ្តប់លើគម្រោងរបស់វិស័យឯកជនទាំងអស់នោះទេ ដែលគម្រោងទាំងនេះអាចមានហានិភ័យច្រើន ដែរ។ |
| ជម្រើសទី៣ | មិនគួរឲ្យកត់សម្គាល់ | អ្នកផ្សេងទទួលរងចំពោះការបំពុលបរិស្ថាន(កត្តាសាយភាយ) ដូចនេះយុទ្ធនាការអប់រំមិនសូវមានប្រសិទ្ធភាព។ |

## ៤.៥. តើមានផលប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ? មិនមាន

មិនមានផលប៉ះពាល់ដល់ការប្រកួតប្រជែងគួរឲ្យកត់សម្គាល់ទេ។

## ៤.៦. តើមានផលប៉ះពាល់លើសមធម៌យេនឌ័រដែរឬទេ?

តើបញ្ញត្តិកម្មនេះមានឥទ្ធិពលមកលើស្ត្រី(បុគ្គលនិងស្ត្រីជាម្ចាស់ធុរកិច្ច) ច្រើនជាងបុរស? មាន

ការបំពុលបរិស្ថានប៉ះពាល់បុរសនិងស្ត្រីផ្សេងគ្នា។ នៅប្រទេសកម្ពុជា ជាទូទៅស្ត្រីធ្វើស្រែចំការ រីឯបុរសជាអ្នកនេសាទ និងធ្វើក្នុងផលិតកម្ម។ ក៏ប៉ុន្តែ ប្រជាពលរដ្ឋប្រមាណ៨០%ជាកសិករ ដូច្នេះគ្រោះមហន្តរាយបរិស្ថានអាចប៉ះពាល់ស្ត្រីច្រើនជាង។

តើមានផលប៉ះពាល់គួឲ្យកត់សម្គាល់ឬទេ? មាន

| មើលខាងលើ |
|---|

តើអាចកំណត់ជាបរិមាណនូវផលប៉ះពាល់នេះបានឬទេ? មិនអាច

## ៥. កិច្ចពិគ្រោះយោបល់បឋម

| ក្រុម | សហគ្រាស | វិធីសាស្ត្រ | សង្ខេបទស្សនៈ |
|---|---|---|---|
| ក្រុមហ៊ុន | ១. MH Bio Energy<br>២. Colben Enargy<br>៣. Cambodian Brewery<br>៤. Chantex garments<br>៥. Senabo garment | កិច្ចប្រជុំ<br>កម្រងសំណួរ | ទោះបីជាគោលការណ៍ ក្រុមហ៊ុនគាំទ្រដំណើរការ IEIA/EIA ប៉ុន្តែពួកគេរិះគន់ចំពោះការងាររដ្ឋបាល ពីព្រោះពួកគេត្រូវទទួលនូវការធ្វើអធិការកិច្ចច្រើនពីសំណាក់ក្រសួងផ្សេងៗ។ ម្យ៉ាងទៀតអ្នកខ្លះបាននិយាយថាលក្ខខណ្ឌតម្រូវមិនមានតម្លា ភាព។ |
| អង្គការក្រៅរដ្ឋាភិបាល | ១. PACT Cambodia<br>២. Live & Learn Cambodia | កិច្ចប្រជុំ | ជាទូទៅរិះគន់លើដំណើរការ IEIA/EIA ។ ការសម្រេចមិនផ្អែកលើរបាយការណ៍ IEIA/EIA។ ខ្វះខាតជំនាញឯកទេសខាងEIA |
| រដ្ឋាភិបាល | ក្រសួង ស្ថាប័ន ៖<br>CDC / MIME / MAFF / MoC / MoT / MoWRAM | | មិនបានពិគ្រោះយោបល់ ប៉ុន្តែលក្ខខណ្ឌតម្រូវត្រូវបានសិក្សា។ ពិគ្រោះជាមួយ MIME លើការអនុវត្ត។ |
| យេនឌ័រ | ក្រុមស្ត្រី<br>MWA | ទូរស័ព្ទ | |

| | | | |
|---|---|---|---|
| អ្នកជំនាញ | អ្នកពិគ្រោះយោបល់ | កិច្ចប្រជុំ | ដំណើរការIEIA/EIA មានការពេញចិត្តទាប បើធៀបទៅនឹងប្រទេសជិតខាង។ MoE មានការបទបែនចំពោះការត្រួតពិនិត្យលើដំណើរការនេះ ដោយគ្មានការពន្យាឬផ្អាក គម្រោង។ |

## ៦.សន្និដ្ឋាន

### ៦.១ សេចក្ដីសង្ខេបនៃការចំណាយបន្ថែម និងផលចំណេញ

| ជម្រើស | បន្ទុកចំណាយរបស់វិស័យឧស្សាហកម្ម | បន្ទុកចំណាយរបស់វិស័យសាធារណៈ | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១ | គួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី២ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ |
| ជម្រើសទី៣ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ |

### ៦.២. តើចាំបាច់ធ្វើ RIS ដែរឬទេ? ចាំបាច់

ដោយហេតុថា ការវាយតម្លៃបឋមនៃអនុក្រឹត្យនេះ សម្រាប់តែការសិក្សាប៉ុណ្ណោះ យើងមិនត្រូវការធ្វើ RIS ពេលនេះទេ។ ប៉ុន្តែ RIS នឹងត្រូវរៀបចំនៅពេលក្រោយ សម្រាប់ការអនុវត្តផងដែរ។

### ៦.៣. ជម្រើសដែលបានជ្រើសរើស (សូមអធិប្បាយអំពីជម្រើស)

អនុក្រឹត្យEIA (មើលទំព័រទី១ អធិប្បាយ)

Skt

| លក្ខណៈវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានបន្ទុកចំណាយអប្បបរមាសម្រាប់វិស័យឧស្សាហកម្ម និងសហគមន៍ដែរឬទេ? | ទេ | បន្ទុកចំណាយរបស់អនុក្រឹត្យនេះខ្ពស់ជាង (ប្រហែល ៤០០ ០០០ ដុល្លារ ក្នុងមួយឆ្នាំ) ជម្រើសផ្សេងទៀត។ ប៉ុន្តែ មានជម្រើសដែលមានបន្ទុកចំណាយទាបជាង (កិច្ចសន្យាការពារបរិស្ថាន) សម្រាប់ក្រុមហ៊ុនតូចៗ។ |
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | មែន | ជម្រើសទី២ វិសាលភាពមានកំណត់។ ជម្រើសទី៣ មិនមានប្រសិទ្ធភាព។ |
| តើវាជាជម្រើសដែលមានហានិភ័យអប្បបរមាសម្រាប់សាធារណៈដែរឬទេ? | មែន | |

ប្រសិនបើចម្លើយទាំងអស់សុទ្ធ "មែន" សូមបន្តទៅចំណុចទី៧។
ប្រសិនបើមានចម្លើយណាមួយខាងលើ"មិនមែន"តើហេតុអ្វីបានជាជម្រើសនេះត្រូវបានជ្រើសរើស?
*(សូមគូស " ✓ " ក្នុងប្រអប់មួយ)*

☑ ទោះបីជាលក្ខណៈវិនិច្ឆ័យមួយឬពីរខាងលើអវិជ្ជមាន តែការរួមបញ្ចូលគ្នានៃលក្ខណៈវិនិច្ឆ័យទាំងអស់មានលក្ខណៈសមស្រប។ ចូរផ្តល់អំណះអំណាង និងបន្តទៅចំនុច៧។

ទោះបីបន្ទុកចំណាយរបស់អនុក្រឹត្យខ្ពស់ ប៉ុន្តែវាបានប៉ះប៉ូវវិញដោយផលចំណេញ។ ម្យ៉ាងទៀត បន្ទុកចំណាយទាបសម្រាប់ក្រុមហ៊ុនតូច ដោយសារពួកគេអាចជ្រើសរើសធ្វើកិច្ចសន្យាការពារបរិស្ថាន។

## ៧. ការអនុវត្ត

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើសៈ

### ៧.១. តើវិធានការអ្វីត្រូវបានជ្រើសរើស ដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អ ក្នុងអំឡុងពេលនៃប្រតិបត្តិការ?

មានជម្រើសមួយសម្រាប់ក្រុមហ៊ុន ចំពោះក្រុមហ៊ុនដែលមានហានិភ័យទាបអាចជ្រើសរើសធ្វើកិច្ចសន្យាការពារបរិស្ថានជំនួសឲ្យការធ្វើ IEIA / EIA។

MoE ជំរុញការផ្សព្វផ្សាយពីEIA ដល់ធុរកិច្ចទាំងឡាយ។

| ដំណើរការ | ឈ្មោះ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|
| រៀបចំដោយ (ក្រសួងពាក់ព័ន្ធ) | | | 29/08/2012 |
| ត្រួតពិនិត្យដោយ (ORIA) | | | 30/08/2012 |
| | | | 31/8/2012 |
| | | | 03/9/2012 |
| ឯកភាពដោយ (ORIA) | | | 05/09/12 |
| បញ្ចូលទិន្នន័យដោយ | | | 30/08/2012 |
| បញ្ចូលក្នុងគេហទំព័រដោយ | | | 06/9/12 |